# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយឈ្មោះ ជា ទូច ភេទប្រុស អាយុ៩៦ឆ្នាំ

**មុខងារសម័យខ្មែរក្រហមៈ «ពេទ្យ»**

**រស់នៅភូមិទំនប់លើ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ**

**ខែសីហា ឆ្នាំ២០១១**

**សម្ភាសន៍ដោយៈ ដាត កុសល**

**០០:២៨:៣៦**

**១៤ទំព័រ**

កុសលៈ ខ្ញុំសុំចាប់ផ្តើមសួរពូ ពូឈ្មោះអីពេញ?

ទូចៈ ជា ទូច ។

កុសលៈ ជា ទូច អក្សរ«ទ» នឹង?

ទូចៈ បាទ ។

កុសលៈ ជា ទូច ។ ថ្ងៃខែឆ្នាំកំណើតលោកពូនៅចាំបានទេ?

ទូចៈ អត់ចាំទេ ទាល់តែមើលអត្រានុកូលដ្ឋាន បានដឹង ។

កុសលៈ កើតនៅឆ្នាំប៉ុន្មាន? លោកពូអាយុប៉ុន្មានហើយឆ្នាំនេះ?

ទូចៈ អាយុ៩៦ ។

កុសលៈ ទីកន្លែងភូមិកំណើត?

ទូចៈ ភូមិកំណើត ។

កុសលៈ នៅភូមិអីគេ?

ទូចៈ ភូមិក្បាលអូរ ។

កុសលៈ ក្បាល?

ទូចៈ បាទ!

កុសលៈ ក្បាលអូរ ។

ទូចៈ ជាងទងឃុំ ។

កុសលៈ ឃុំជើងទង?

ទូចៈ ស្រុកត្រាំកក់ ។

កុសលៈ ស្រុកត្រាំកក់ ខេត្តតាកែវ?

ទូចៈ ខេត្តតាកែវ ។

កុសលៈ ភូមិបច្ចុប្បន្ន?

ទូចៈ ភូមិទំនប់លើ ។

កុសលៈ ឃុំ?

ទូចៈ ឃុំត្រពាំងព្រៃ ។

កុសលៈ ពូស្គាល់ពូណាតដែរ? មេឃុំ ។

ទូចៈ ស្គាល់ ។

កុសលៈ ខ្ញុំនិយាយលេងជាមួយគាត់ប៉ុន្មានដង ដល់តែមាន់ទេគាត់ ។ ត្រពាំងព្រៃ ស្រុកអីខ្ញុំដឹងអស់ហើយ ។ មានឈ្មោះហៅផ្សេង ហៅក្រៅទេពូ?

ទូចៈ អត់ ។

កុសលៈ ចុះកាលទទួលដំណោកសព្វថ្ងៃ ទទួលបានធម្មតាទេ?

ទូចៈ ធម្មតា ។

កុសលៈ អត់មានលំបាកអីទេ? ទទួលដំណោកអត់មានបញ្ហាទេ?

ទូចៈ អត់មានបញ្ហាអីទេ ។

កុសលៈ ការចងចាំនូវព្រឹត្តិការណ៍ផ្សេងៗ ពូនៅចាំបានល្អទេ? តិចតួច ខ្លាំង?

ទូចៈ អត់ទេ ភ្លេច ។

កុសលៈ មិនសូវល្អ ភ្លេចភ្លាំងច្រើន ។

ទូចៈ បាទ!

កុសលៈ ពិបាកចងចាំ ខ្លាំងបន្តូរ ។ ហេតុអីពូមានប៉ះទង្គិចអី? ដោយសារតែអាយុចាស់ ឬដោយសារពូគ្រោះថ្នាក់ក្នុងពេលទាហានហ្នឹង?

ទូចៈ មួយរោគតែម្តងអត់មានត្រូវរបួសអីទេ ។

កុសលៈ រោគ ឈឺអីពូ? ឈឺអីគេ?

ទូចៈ កាលហ្នឹងគ្រុនចាញ់តែម្តង មួយខែ២-៣ដង លេបថ្នាំវាអត់ដាច់ ។

កុសលៈ ចាញ់ទៅបាក់រហូត ។

ទូចៈ បាក់ ។

កុសលៈ ពេលខ្លះមានអារម្មណ៍ថាដូចចង់នៅម្នាក់ឯងអីទេ? មានធ្លាប់អីចឹងទេ? មានអារម្មណ៍មិនសូវរវីរវល់ មិនចង់ទាក់ទងអ្នកដទៃពេលខ្លះ? ញឹកញាប់ តិច ឬច្រើន?

ទូចៈ	អត់ចង់ ចង់នៅតែគ្នាច្រើន ឲ្យសប្បាយចិត្ត ឃើញគេគ្រាវៗចេះតែ ។

កុសលៈ	គ្រាវៗអត់អីវិញ ។

ទូចៈ	បាទ!

កុសលៈ	មានសុបិន យល់សប្ដិអាក្រក់អីជារើយៗ?

ទូចៈ	អត់ទេ ។

កុសលៈ	មានចេះតែគិតពីព្រឹត្តិការណ៍អីមួយគួរឲ្យភ័យខ្លាចដែលទេ?

ទូចៈ	អត់ទេ ។

កុសលៈ	ល្អ ។

ទូចៈ	ព្រោះខ្ញុំមិនមានអីភ័យខ្លាច ខ្លាចតែព្រំដែនទេ ។

កុសលៈ	ឆាប់ខឹង? ខ្លាចព្រំដែន ជិតព្រំដែន?

ទូចៈ	បាទ!

កុសលៈ	មានអារម្មណ៍ចេះតែឆាប់ខឹង?

ទូចៈ	អត់អីទេ ។

កុសលៈ	ចេះតែចង់ផ្ទុះកំហឹង?

ទូចៈ	អត់អី ។

កុសលៈ	មានអារម្មណ៍ចេះតែប្រុងខ្លួនជានិច្ច ចេះតែប្រយ័ត្នខ្លាចគេយក?

ទូចៈ	អត់អីទេ មានត្រូវខ្លាចអី ខ្លាចតែព្រំដែនហ្នឹងកើតសង្គ្រាមមិនដឹងរត់ទៅណាចេះ គិតតែប៉ុណ្ណឹងឯង ។ អ្នកជិតខាង "ខ្លាចវាមិនសូវខ្លាច អ្នកចាស់ៗ គេអ្នកចំណូលមកថ្មី គ្រាន់តែលឺប្រោករត់បាត់ យើងផ្ទះសំបែងនៅនេះហើយ ដីធ្លីនៅនេះ ទៅមានតែ ស្លាប់" ។ គ្រាន់តែបារម្ភថាព្រំដែននេះមានសង្រ្គាមមិនដឹងរត់ទៅណា ទៅស្រុកក្នុងវាលំបាក យើងអត់ដីអត់ធ្លី ។ អ្នកជិតខាង "គ្មានដីគ្មានផ្ទះសំបែង" ។

កុសលៈ	អីចឹងមុនឆ្នាំ១៩៧៥ គ្រួសារលោកពូចាត់ទុកថា ក្រ មធ្យម បង្គួរ ឬក៏មាន?

ទូចៈ	ក្រ ។

កុសលៈ	កាលនោះរៀបការនៅ? កាលឆ្នាំ១៩៧៥?

ទូចៈ	ខ្ញុំនៅក្មេងតូចៗ ។

កុសលៈ	តូចៗ?

ទូចៈ	បាទ!

កុសលៈ	អីចឹងអត់ទាន់ទេ ។

ទូចៈ បាទ!

កុសលៈ អត់ទាន់មានកូនទេ?

ទូចៈ អត់ទេ ។ មកនៅនេះមកតាមគេហ្នឹង ។

កុសលៈ មុនរបប៣ឆ្នាំហ្នឹង លោកពូធ្វើអីដែរ? កូនសិស្ស នៅរៀននៅឡើយ? ឬកសិករ?

ទូចៈ មុន៣ឆ្នាំ នៅរៀន ។

កុសលៈ រៀនថ្នាក់ទីប៉ុន្មានកាលហ្នឹង?

ទូចៈ ថ្នាក់ទី១០ ។

កុសលៈ រៀនបានខ្ពស់ដែរ?

ទូចៈ ទី១០ចាស់យើង ។

កុសលៈ ទី១០ចាស់ ស្មើរនឹងទីប៉ុន្មានឥលូវ? ទី៣ ទី៤?

ទូចៈ មិនដឹងថ្នាក់ទីប៉ុន្មាន ។

កុសលៈ នៅបឋមសិក្សា អត់ទាន់ចប់? ពេលហ្នឹងពូមានចូលបដិវត្តន៍ ជួយប្រទេសជាតិទេកាលហ្នឹង? ពូចូលទាហានពេលណា?

ទូចៈ កាលហ្នឹងចូលនឹងគេដែរ?

កុសលៈ ចូលពេលណា? ឆ្នាំណា?

ទូចៈ ចូលឆ្នាំ១៩៧៤ហ្នឹង ។

កុសលៈ មូលហេតុអីបានពូចូលកាលហ្នឹង?

ទូចៈ ចេះតែផ្ដើលតាមគេតាមឯង ។

កុសលៈ ផ្ដើលតាមគេតាមឯង? ផ្ដើលថាម៉េចទៅ?

ទូចៈ ឃើញគេចូលច្រើន ក៏ចូលនឹងគេទៅ ។

កុសលៈ អ្នកភូមិគេចូលអស់?

ទូចៈ បាទ!

កុសលៈ ចុះលោកពូចូលមានដែលលឺថាគេចូលដើម្បីផ្ដួលរបប លន់ នល់ ដូចថាពួកចក្រពត្តិអាមេរិចកាំង មានលឺគេ? មានគេប្រកាសទេ?

ទូចៈ លឺថាអីចឹង លឺថាគេធ្វើបដិវត្តន៍រំដោះវណ្ណៈជិះជាន់ ។

កុសលៈ ស្រុកភូមិលោកពូពេលហ្នឹងមានពួកអាមេរិចកាំងទម្លាក់គ្រាប់បែកត្រូវដែរ? ជិនាន់ហ្នឹង? ដឹងទេ? ព្រោះ១៩៧៣ទម្លាក់គ្រាប់បែកដល់ហើយ ។

ទូចៈ ទម្លាក់ អាមិចទម្លាក់ចំភូមិ ។

កុសលៈ ចំភូមិ មានបាត់បង់ទ្រព្យសម្បត្តិអីដែរ?

ទូចៈ ស្លាប់ប្រជាជនអស់ប៉ុន្មាននាក់ ។

កុសលៈ ស្លាប់ច្រើនទេ?

ទូចៈ បាទ! ផ្ទះល្វែងនេះ ទម្លាក់ធុងសាំង ទម្លាក់គ្រាបណាប៉ាល់ ដើមដូងបាក់អស់ ។

កុសលៈ ចុះគ្រួសារលោកពូពេលហ្នឹងទទួលការខូចខាត គ្រោះថ្នាក់ទេ?

ទូចៈ ក្នុងគ្រួសារខ្ញុំអត់អី ។

កុសលៈ នៅត្រាំកក់ហ្នឹងពេលហ្នឹង?

ទូចៈ បាទ!

កុសលៈ ពូមានអារម្មណ៍ម៉េចដែរពេលហ្នឹង ឃើញអ្នកស្រុកអ្នកភូមិចូលបដិវត្តន៍គ្រប់គ្នា?

ទូចៈ បាទ!

កុសលៈ តើមូលហេតុហ្នឹងដែលធ្វើឲ្យថាមានអារម្មណ៍ចូលរំដោះប្រទេសជាតិយើងពេលហ្នឹង?

ទូចៈ បាទ!

កុសលៈ ពេលហ្នឹងចេះតែចូលតាមគ្នាទៅ គ្មានជំរើសអីទេ?

ទូចៈ អត់មានជំរើសអីទេខ្ញុំចេះតែចូល ឃើញគេទៅដូចសប្បាយ ។

កុសលៈ ពូកាន់សាសនាអីដែរ? ព្រះពុទ្ធ?

ទូចៈ ព្រះពុទ្ធ ។

កុសលៈ ក្នុងរបប៣ឆ្នាំកាន់ខាងព្រះពុទ្ធដែរ ឬអត់ទេ? លែង?

ទូចៈ ឥលូវក៏កាន់សាសនាព្រះពុទ្ធ ។

កុសលៈ ពូខស្បាហ៍ទៅវត្តដែរ?

ទូចៈ ទៅញឹកដែរ ។

កុសលៈ ភ្ជុំនេះទៅដែរ?

ទូចៈ បាទ!

កុសលៈ ក្រោយមកទៀតពូធ្វើអី ពេលប្រទេសរំដោះ? ឆ្នាំ១៩៧៥ហើយ?

ទូចៈ ប្រទេសរំដោះខ្ញុំចូលរៀនពេទ្យនឹងគេ ។

កុសលៈ គេឲ្យរៀនពេទ្យ?

ទូចៈ បាទ! រៀនបាន១ឆ្នាំ ដល់វៀតណាមចូលមកក៏រត់មកព្រំដែនមក ។

កុសលៈ អីចឹងចូលរៀន រៀនឆ្នាំណាពេទ្យហ្នឹង?

ទូចៈ ឆ្នាំ១៩៧៥-១៩៧៦ ។

កុសលៈ សព្វថ្ងៃក៏ពូធ្វើពេទ្យដែរ បន្តវិជ្ជាជីវៈពេទ្យហ្នឹងរហូតទៅ?

ទូចៈ អត់ទេ ឥលូវដាច់រយៈ ។

កុសលៈ កាលទៅរៀនពេទ្យគេឲ្យរៀនអីខ្លះ?

ទូចៈ ពេទ្យខ្មែរក្រហម គេឲ្យដូចថាគ្រាន់តែឲ្យបោកខោអាវអ្នកឈឺ ។

កុសលៈ ថ្នាំអីម៉េចដែរ? រៀនពីផ្សំថ្នាំផ្សំអី?

ទូចៈ ថ្នាំគេមានថ្នាំបុរាណគេ ថ្នាំឫសឈើឫសព្រៃ យកមកស្ងួរយកមកអី ហើយមានថ្នាំសម័យយើងខ្លះ ។

កុសលៈ ហើយពេលដែលរៀនហ្នឹង រៀនរយៈប៉ុន្មានខែ បានចូលធ្វើពេទ្យ?

ទូចៈ ខ្ញុំអត់មានរៀនអីផង រៀនតែប៉ុណ្ណឹង ។

កុសលៈ គេឲ្យចូលទៅធ្វើពេទ្យទៅ?

ទូចៈ បាទ! ចូលធ្វើពេទ្យនៅជាមួយគ្នាទាំងអស់ ទាំងពេទ្យទាំងបុគ្គលិកទាំងអស់ ។

កុសលៈ ពេទ្យនៅណាកាលហ្នឹង?

ទូចៈ នៅនេះ ស៊ីសុផុន ។

កុសលៈ ដល់រៀនពេទ្យហើយគេបញ្ជូនពីនោះមក ឲ្យមកនៅតាម ស៊ីសុផុន?

ទូចៈ អត់តេ ។

កុសលៈ ស៊ីសុផុន បាត់ដំបងហ្នឹង?

ទូចៈ បាទ! នៅហ្នឹងបាន១ឆ្នាំ កើតសង្គ្រាមទៅ ។

កុសលៈ ពេលវៀតណាមចូលមកហ្នឹង?

ទូចៈ បាទ!

កុសលៈ ហើយពូក៏បន្តធ្វើពេទ្យទៀតទៅ? អីចឹងរហូតទៅ?

ទូចៈ តមកឥលូវអត់មានធ្វើពេទ្យផង ធ្វើទាហាន កាលចេញពីហ្នឹងមកនៅតាមព្រំដែន ។

កុសលៈ ធ្វើទាហាន?

ទូចៈ ធ្វើទាហាន ។

កុសលៈ ឆ្នាំណា? ១៩៧៩?

ទូចៈ ១៩៧៩ ។

កុសលៈ ដែលវ៉ៃជាមួយពួកវៀតណាមទេដឺនាន់ហ្នឹង?

ទូចៈ វ៉ៃ ។

កុសលៈ វ៉ៃតែញ៉ុយ?

ទូចៈ សើច ។

កុសលៈ ពួកថៃយ៉ាងម៉េចដែរតាមព្រំដែន យើងមានការពារបាន?

ទូចៈ ថៃកាលមុនដំបូងយើងចូលមកវារករឿងដែរហ្នឹង មិនដឹងមេទាក់ទងយ៉ាងម៉េចត្រូវគ្នាក៏លែងអី ។

កុសលៈ ចុះពេលហ្នឹងពូដែលចុះដល់ប្រាសាទព្រះវិហារដែរ?

ទូចៈ ខ្ញុំអត់ដែលដឹងទេ ព្រំដែន ។

កុសលៈ សព្វថ្ងៃបើសិនជាស្រុកថៃ ស្រុកសៀម វាចូលមកលុកលុយដល់ប្រាសាទព្រះវិហារ ពូធ្វើយ៉ាងណា?

ទូចៈ ធ្វើយ៉ាងណាស្រេចលើរដ្ឋាភិបាលយើង ។

កុសលៈ ចុះបើរដ្ឋាភិបាលថាឲ្យ?

ទូចៈ រដ្ឋាភិបាលឲ្យដកៗ រដ្ឋាភិបាលឲ្យនៅៗ ។

កុសលៈ ឲ្យវ៉ៃៗ?

ទូចៈ បាទ ។

កុសលៈ ហ៊ានចូលទាហានទៀតទេ? ការពារជាតិ?

ទូចៈ គ្រាន់តែយ៉ាប់ចាស់បន្តិច ។

កុសលៈ កូន ឲ្យចូលធ្វើទាហានទៀតទេ? គាត់ធ្វើទាហានហើយ?

ទូចៈ អត់នៅរៀន ។

កុសលៈ រឿងថៃមិនទាន់ចប់នៅឡើយ មិនដឹងយ៉ាងម៉េច ចាំមើល វាថាមិនទាន់នឹងន័រនៅឡើយ មិនដឹងយ៉ាងម៉េចទៀតចាំមើល ។ ខ្ញុំសួរលោកពូមួយថាក្រោយមកទៀត ពេលវៀតណាមចូលមក ៧៩ហ្នឹងពូរត់មកតាមគេទៅ?

ទូចៈ បាទ ។

កុសលៈ ហេតុអីមិនរត់ទៅក្នុងវិញ?

ទូចៈ ខ្ញុំនៅតាមព្រំដែន ។

កុសលៈ ហេតុអីមិនរត់ទៅក្នុង?

ទូចៈ ព្រោះខ្ញុំខ្លាច ។

កុសលៈ ម៉េចមិនរត់ទៅតាកែវ?

ទូចៈ រត់ទៅតាកែវឆ្ងាយណាស់ មិនដឹងប៉ុន្មានថ្ងៃដល់ទេ ។

កុសលៈ ពូរៀបការឆ្នាំណា?

ទូចៈ ឆ្នាំ៨០ ។

កុសលៈ អាយុប៉ុន្មានពេលហ្នឹង?

ទូចៈ អាយុប៉ុន្មានទេ ២៥-២៦ ។

កុសលៈ លោកពូមេភូមិពេលគាត់រៀបការ ពេលហ្នឹងគេតំរូវឲ្យរៀប១៥គ លោកពូមានសិទ្ធិជ្រើសរើស អត់អីទេ?

ទូចៈ ខ្ញុំជ្រើសរើសខ្លួនឯង ។

កុសលៈ គាត់អត់ទេ គេតំរូវឲ្យដាក់១៥គូ រើសមិត្តនារី១៥មក ជួបគ្នា ឥលូវគាត់នៅសុខដល់ឥលូវ មានអីគាត់ ។ លោកពូមានដែលលឺដូចថា ឆ្លងកាត់សង្គ្រាមមកអីចឹង ខ្ញុំសួរសំនួរសំខាន់មួយថា ធ្វើម៉េចឲ្យមានការផ្សះផ្សារជាតិ ។ ខ្ញុំចង់និយាយថាពីមុនមកតំបន់នេះជាតំបន់អតីត ជាតំបន់ក្តៅ ហើយតំបន់មួយខាងក្នុង ហើយយើងខ្មែរវ៉ៃខ្មែរ វ៉ៃគ្នា មានអ្នកជាន់មីនដាច់ដៃ ដាច់ជើងអស់ ធ្វើម៉េចទៅមានការផ្សះផ្សារ ធ្វើម៉េចមានសន្តិភាពជាប់លាប់រហូតទៅ ពូយល់ធ្វើយ៉ាងម៉េចទៅ?

ទូចៈ អាហ្នឹងទាល់តែទំនាក់ទំនងខាងក្នុងនិងខាងក្រៅ ទំនាក់ទំនងគ្នាទៅ ដល់អីចឹងខាងក្រៅក៏លំបាក ខាងក្នុងក៏លំបាកក៏ដោយ ផ្សះផ្សារគ្នាទៅ ។

កុសលៈ ឲ្យយល់ពីការលំបាកគ្នាវិញទៅមក?

ទូចៈ យល់ចិត្តគ្នារៀងខ្លួន ព្រោះខាងនេះក៏គ្នាមិនចង់លំបាក ខាងក្នុងក៏មិនចង់លំបាកដូចគ្នាអីចឹង យល់ចិត្តគ្នា ផ្សះផ្សារគ្នាទៅ ហើយកើតសង្គ្រាមក៏មិនចំណេញដល់ខ្លួនឯង ។

កុសលៈ ពូយល់ថាអ្នកណាជាអ្នកទទួលខុសត្រូវក្នុងរបប៣ឆ្នាំ? ក្នុងរបប៣ឆ្នាំ ពូជឿថាមានខ្មែរយើងស្លាប់ច្រើន ជឿទេថាមានអំពើឃាតកម្មកើតឡើង?

ទូចៈ ខ្ញុំអត់ដឹង ។

កុសលៈ អត់បានដឹងទេ?

ទូចៈ បាទ!

កុសលៈ ឥលូវពូជឿទេ មានដែលទៅភ្នំពេញឃើញទេ?

ទូចៈ អត់ ។

កុសលៈ ប៉ុន្តែបានដឹងលឺថាមានការកាប់សម្លាប់ដូចនៅគុកទួលស្លែង?

ទូចៈ អត់ មិនដែល ។

កុសលៈ អត់ដែលលឺទេ?

ទូចៈ គ្រាន់តែលឺគេនិយាយតៗគ្នា ប៉ុន្តែមិនដែលទៅឃើញ ។

កុសលៈ ចុះអាអូនដែលធ្លាប់ឃើញទេ?

កូនៈ ធ្លាប់រៀន ។

កុសលៈ ធ្លាប់រៀន? គេថាម៉េចខ្លះនៅសាលា?

កូនៈ សៀវភៅគេបើកសៀវភៅខ្មៅនោះឲ្យ ។

កុសលៈ អ៊ូ! សៀវភៅគេចែកឲ្យ សៀវភៅខាងមជ្ឈមណ្ឌលឯកសារទេដឹង?

កូនៈ អីទេ លោក ខាំ

កុសលៈ ខាំ បូលី ។

កូនៈ ហ្នឹងហើយ ។

កុសលៈ អីចឹង ។ មានសៀវភៅហ្នឹងដែរមើល? មានបានមើលទេ?

កូនៈ មើលដែរ ឲ្យតាំងពីឆ្នាំមុន គាត់ចុះមកសាលាអន្លង់វែង ។

កុសលៈ សាលាអន្លង់វែង ។ មានយកឲ្យលោកពូមើលដែរ?

កូនៈ អត់ ។

កុសលៈ យល់យ៉ាងម៉េចដែលកាលហ្នឹង?

កូនៈ មិនដឹងច្បាស់តាមគេ ។

កសលៈ ប៉ុន្តែលោកពូអត់ដឹងទេ? អត់ដែលដឹងថាមានកើតឡើង?

ទូចៈ អត់ដឹង ។

កុសលៈ ធ្លាប់ដឹងថាឥលូវគេមានស្អី តុលាការខ្មែរក្រហម តុលាការកាត់ទោសអី?

ទូចៈ លឺ ស្តាប់វិទ្យុ ប៉ុន្តែមិនដឹងនៅណា គ្រាន់តែលឺៗ ។

កុសលៈ មានដែលតាមដានទេ?

ទូចៈ បាទ! តាមដាន ។

កុសលៈ អីចឹងបានទាក់ទងរឿងការផ្សះផ្សារជាតិ ។ ខ្ញុំចង់សួរថាបណ្តាលប្រទេសផ្សេងៗមកក៏មានឆ្លងកាត់ស្រដៀងប្រទេសកម្ពុជាយើងដែរ ប្រហែលជាពូមិនបានដឹង ខ្ញុំអាចប្រាប់ថានៅប្រទេស រ្វ៉ាន់ដា នៅប្រទេសអាហ្វ្រិក នៅប្រទេសយូហ្គូស្លាវី នៅផ្សេងៗទេ បញ្ហាមួយត្រង់ថាសង្គ្រាមកើតឡើងហើយ យើងធ្វើម៉េចឲ្យមានការផ្សះផ្សារ ធ្វើម៉េចលាងរបួសហ្នឹងឲ្យវាជា? បញ្ហាកនែងហ្នឹងពូ អ្នកខ្លះគេធ្វើតុលាការ អ្នកខ្លះគេមានការអត់ឱនទោសគ្នាទៅវិញទៅមក អ្នកខ្លះដូចពូនិយាយម៉ិញថា ត្រូវមានការយោគយល់គ្នាទៅវិញទៅមក ពីក្នុងនិងក្រៅ អីចឹងលោកពូយល់ថារដ្ឋាភិបាលសព្វថ្ងៃចំណាយលុយរាប់លានដុល្លាដើម្បីធ្វើតុលាការ មានប្រយោជន៍ដែលអត់?

ទូចៈ មិនដឹងថាម៉េច ខ្ញុំអត់យល់ដែរ ។

កុសលៈ ពូគិតថាមានសារសំខាន់ទេ?

ទូចៈ ខ្ញុំថាដូចអត់មានអី ព្រោះអ្នកដែលធ្លាប់ធ្វើខុស ងាប់ចង់អស់ហើយ តែបន្តិចសាបរលាបបាត់អស់ហើយ អាក្មេងស្រុករក្រោយមានដឹងអីវា វាគិតតែពីទំរកស៊ី ចិញ្ចឹមគ្រួសាររៀងខ្លួន ។

កុសលៈ លោកពូក៏មិនសូវតាមដានដែល គ្រាន់តែតាមដានវិទ្យុ មែនទេ?

ទូចៈ បាទ!

កុសលៈ នៅក្នុងភូមិស្រុកយើង តើលោកពូយល់ថា ធ្វើម៉េចទៅលោកពូមានអារម្មណ៍ថាទុកចិត្តអ្នកជុំវិញខ្លួន សាមគ្គីនៅក្នុងភូមិមានបញ្ហាអីទេ?

ទូចៈ មិនមានបញ្ហាអី ព្រោះអ្នកស្រុកអ្នកភូមិដូចជាបងប្អូនគ្នា ។

កុសលៈ មានអ្នកចំណូលថ្មីទេពូ?

ទូចៈ អត់សូវមានទេ មានភាគតិច ។

កុសលៈ អត់មានបញ្ហាអីទេ អ្នកចំណូលថ្មីហ្នឹង?

ទូចៈ អ្នកចំណូលថ្មីមកថាចូលស្ទឹងតាមបទ ចូលស្រុកតាមប្រទេស ។

កុសលៈ អីចឹងត្រឡប់ទៅរបប៣ឆ្នាំ ៨ខែវិញ លោកពូយល់ថាលោកពូជាជនរងគ្រោះ ឬជាអ្នកស្នេហាជាតិ សកម្មម្នាក់ដើម្បីបំរើអង្គការ?

ទូចៈ សម័យ៣ឆ្នាំ យើងធ្វើៗដោយមិនពេញចិត្ត ធ្វើឲ្យតែរស់ៗទៅ បើយើងប្រឆាំងគេម៉េចបាន ។

កុសលៈ តើពូជឿជាក់ថាគោលនយោបាយជំនាន់ហ្នឹងគេធ្វើឲ្យប្រទេសយើង ឲ្យគង់វង្ស? កាលហ្នឹងពូជឿជាក់ទេ? ដូចមេដឹកនាំជំនាន់ហ្នឹងក៏គាត់ចង់ការពារប្រទេសយើងពីប្រទេសយួន ពីការឈ្លានពានប្រទេសដទៃ? អីចឹង?

ទូចៈ រឿងហ្នឹងតាមរបបរៀងខ្លួន របបនោះក៏គេថាស្នេហាជាតិ ដល់សម័យយើងឥលូវក៏ស្នេហាជាតិដូចគ្នា ។

កុសលៈ ប៉ុន្តែពូដែលគិតថារបបហ្នឹងដើរទៅផ្លូវត្រូវ ឬយ៉ាងម៉េចដែលគិតទេកាលហ្នឹង?

ទូចៈ ដូចអត់គិតទេ ។

កុសលៈ ធ្វើតាមតែបញ្ជាគេហ្នឹង?

ទូចៈ គេបញ្ជាឲ្យធ្វើអីធ្វើហ្នឹង ។

កុសលៈ គ្រួសារលោកពូពេលហ្នឹងយ៉ាងម៉េច មកនៅជាមួយគ្នាទាំងអស់?

ទូចៈ គ្រួសារខ្ញុំមកជាមួយគ្នា នៅជាមួយគ្នា មកយកគ្នានៅព្រំដែននេះ ជួបគ្នាព្រំដែន ។

កុសលៈ អីចឹងការកាប់សម្លាប់កើតមាននៅជំនាន់ហ្នឹង តើយើងគិតថាជាកំហុសរបស់អ្នកណា ទៅ? កំហុសអ្នកដឹកនាំ?

ទូចៈ កំហុសអ្នកដឹកនាំ ។

កុសលៈ អីចឹងលោកពូគាំទ្រទេនឹងមតិកុំឲ្យមានការកាត់ទោសតទៅទៀត? លើសពី០០២លើស ពីមេដឹកនាំហ្នឹងទៅ យើងកុំឲ្យមានការកាត់ទោសតទៅទៀត តើលោកពូយល់ថាត្រឹមត្រូវ ទេ? ឯកភាពទេ?

ទូចៈ ធ្វើអីចឹងខ្ញុំឯកភាពដែរ ព្រោះមេដឹកនាំចង់យកទៅកាត់ទោសខាងក្រោយហ្នឹង បើយក ទៅមានកូន មានចៅ មានបង មានប្អូនគេ គេចេះតែមានគំនុំហើយ ព្រោះថ្មីៗវាមាន គំនុំតៗគ្នាអត់ចេះចប់ទេ ។

កុសលៈ អីចឹងដើម្បីសន្តិភាពយើងគួរតែបំភ្លេចចោលអតីតកាល?

ទូចៈ គួរបំភ្លេចចោល ។

កុសលៈ អីចឹងអ្វីដែលកើតឡើងនៅរបបហ្នឹង ពូយល់ថាជារឿងមួយចៀសមិនផុត? អាច ចៀសផុតទេ?

ទូចៈ របបហ្នឹងចៀសម៉េចផុត បើវាកាន់កាប់ទូទាំងប្រទេសហើយ យើងរត់ទៅណា យើង ប្រជាជន ។

កុសលៈ កើតមក?

ទូចៈ បាទ!

កុសលៈ ចុះអ្នកដែលបញ្ជាដោយគេគួរតែកាត់ទោសទេ? អ្នកដៃដល់តែទទួលបញ្ជាពីគេមក?

ទូចៈ គាត់ចង់និយាយថាម៉េច?

កុសលៈ ដូចអ្នកទទួលបញ្ជាពីគេមកឲ្យធ្វើ ប្រព្រឹត្តិអំពើធ្វើបាបអ្នកដទៃ តើគាត់គួរយកមក កាត់ទោសទេ? ឬកាត់តែមេដឹកនាំបានហើយ?

ទូចៈ អាហ្នឹងវាក្រោមបញ្ជារបស់គេ គ្នាចេះតែធ្វើហើយ ទាំងគាត់ទាំងខ្ញុំ តែគេបញ្ជាឲ្យទៅ ណា ទៅហ្នឹងហើយ ។

កុសលៈ ឲ្យតែរស់ៗហើយ ។

ទូចៈ បេ់យើងមិនធ្វើគេ គេធ្វើយើង វាអីចឹង ។

កុសលៈ រាល់ថ្ងៃពូយល់ថាខ្លួនគោរពតាមរដ្ឋាភិបាល បើរដ្ឋាភិបាលធ្វើអ្វីខុសដាក់មកមិនត្រូវពូ ហ៊ានជំទាស់ទេ?

ទូចៈ ប្រជាជនដូចជាមិនហ៊ានដឹងទាស់ទេ មានតែខ្សឹបខ្សាវគ្នាអីចឹង ។

កុសលៈ រដ្ឋាភិបាលដាក់មកម៉េចគឺធ្វើតាមហ្នឹងហើយ ។

ទូចៈ បើធ្វើមិនស្រួលមានតែខ្សឹបខ្សាវគ្នាចុះឡើងៗ ។

កុសលៈ ពូយល់ថារដ្ឋាភិបាលបច្ចុប្បន្ន និងអាជ្ញាធរភូម-ឃុំ ផ្ដល់សុវត្ថិភាពគ្រប់គ្រាន់ដល់គ្រួសារពូហើយនៅ? បានកំរិតណា តិច ឬក៏ច្រើន?

ទូចៈ អាចរស់នៅបាន ។

កុសលៈ ភាគរយប៉ែតសិបភាគរយ ចិតសិបភាគរយហើយនៅ?

ទូចៈ ចិតសិបភាគរយ ។

កុសលៈ ខ្វះខាតអីខ្លះ?

ទូចៈ ខ្វះខាតមិនដឹងថា រដ្ឋាភិបាលខ្វះខាត ឬក៏ថ្នាក់ដឹកនាំខាងក្រោមខ្ញុំអត់ដឹង ។

កុសលៈ ចំណុចណាខ្លះដែលខ្វះខាត?

ទូចៈ ខ្វះខាតដូចជា ឧទាហរណ៍ដូចជាពន្ធម៉ូតូ ឬពន្ធឡាន រដ្ឋាភិបាលដាក់កំណត់ថា បង់ផ្លូវម៉ូតូមួយ បួនពាន់ ប្រាំពាន់ មកដល់នេះឃើញយកប្រាំមួយពាន់ ប្រាំពីរពាន់ ។

កុសលៈ ប៉ុន្តែនិយាយជារួម ស្ថានភាពលោកពូមានលនឹងហើយនៅ រាល់ថ្ងៃហ្នឹងលំនឹង មានការទុកចិត្ត លំនឹងថាយើងអាចប្រកបរបររស់នៅ សុខុមរម្យនាទៅមុខ មិនចាំបាច់ភ័យខ្លាចដូចពីមុន ។

ទូចៈ អាហ្នឹងស្រេចលើរដ្ឋាភិបាល បើរដ្ឋាភិបាលធ្វើឲ្យប្រជាជនសុខៗ បើរដ្ឋាភិបាលធ្វើឲ្យប្រជាជនមិនសុខ វាអត់សុខ ។

កុសលៈ ប៉ុន្តែឥលូវពូមានលំនឹងលើគ្រួសារខ្លួនឯង មានលំនឹង មានម្ចាស់ការលើខ្លួនឯងទេ?

ទូចៈ បាទ! មាន ម្ចាស់ការលើគ្រួសារ ក្នុងក្រុមគ្រួសារ មិនចង់ទៅណាទៀត ចង់នៅហ្នឹងតែម្ដង សុខុមរម្យនានៅភូមិហ្នឹងតែម្ដង ។

កុសលៈ ពីមុនមកចេះតែសង្គ្រាម ចេះតែរត់ មានលំនឹងទេ?

ទូចៈ ពីមុនមករកទិសដៅអត់ដឹង ចេះតែទៅនេះទៅនោះ ឥលូវប្រហែលជាចាក់គ្រឹះនៅហ្នឹងតែម្ដង ។

កុសលៈ មិនចង់ទៅណាទៀតទេ ។

ទូចៈ លែងចង់ទៅណាហើយ ។

កុសលៈ ចង់និយាយថាពូមានសង្ឃឹមច្រើនជាង ដែលថាបានចូលមករាជរដ្ឋាភិបាលបច្ចុប្បន្ន ពូមានសង្ឃឹមខ្លាំងជាងពីមុនមក?

ទូចៈ បាទ! មានសង្ស៊ឹម ។

កុសលៈ ពីមុនមកវាវិញមានលំនឹង?

ទូចៈ ពីមុនអត់លំនឹង ឥលូវសង្ស៊ឹមលើរដ្ឋាភិបាល ។

កុសលៈ ពូមានបារម្ភពីបញ្ហាជនជាតិបរទេសដែលចូលមកប្រទេសរបស់យើង ប្រកបរបរអាជីវកម្ម ក៏ដោយ ពូមានបារម្ភទេ?

អ្នកជិតខាងៈ ទេ អាហ្នឹងបារម្ភច្រើនដែលហ្នឹង ។ បើលែងគាត់សួរខាងនោះទេ តែខ្ញុំចេះ ។

កុសលៈ ចាំខ្ញុំសួរអ៊ីទៀត ។

អ្នកជិតខាងៈ ឧទាហរណ៍ ដូចជានៅស្មាច់ក៏ដោយ នៅភ្នំយើងក៏ដោយ វាមកវាយកដូចធ្វើកាស៊ីណូ អត់មានតិចឆ្នាំទេ សុទ្ធតែ៧០-៨០ឆ្នាំ, ៩០ឆ្នាំ ដល់យូរៗទៅអាជីព្រំដែនហ្នឹងទៅគេ អស់រលីង បាត់ទឹកដីអស់ទៀត ។

កុសលៈ លោកពូឯកភាពអ៊ីទេ?

ទូចៈ បាទ!

កុសលៈ អ៊ីចឹងពូគាំទ្រឲ្យរដ្ឋាភិបាលកាត់បន្ថយនូវឥទ្ធិពលរបស់ជនបរទេស? តិច ច្រើន ខ្លាំង?

ទូចៈ បើកាត់ខ្លាំងពេកក៏យើងឯកោ បើធូរពេកក៏យើងបាត់បង់ដី អ៊ីចឹងធ្វើមធ្យម ទំនាក់ទំនង អ្នកភូមិផងរបងជាមួយ ។

កុសលៈ អ៊ីចឹងមធ្យម?

ទូចៈ បាទ! មធ្យម ។ អ្នកជិតខាង "ដូចនៅជំនាន់ខ្មែរក្រហម អាត្រង់ពើយនេះ ដីយើង ហួសទៅនោះ ហួសឆ្ងាយណា ដូចនៅម៉ុំសាមសែន សុទ្ធតែជ្រៅៗ ដល់ឥលូវគេនៅ ពើយៗអស់បាត់ អ៊ីចឹងបានសេចក្ដីថាទឹកដីខ្មែរយូរៗទៅចេះតែរួញទៅ ចាញ់សង្គ្រាម វាយកលេសកើតសង្គ្រាម ទៅបន្តិចម្ដងៗ បាត់អស់ទឹកដី អាហ្នឹងខ្ញុំនិយាយតែខ្ញុំ មើលឃើញប៉ែកខាងនេះ ប៉ែកខាងយួនអស់ដីងទេ" ។

កុសលៈ អាហ្នឹងក៏ច្រើនដែរ គេថាចេះ ខាងនោះគេយកដីស្រែ នេះទាររកដុំថ្ម ខាងនោះដី ស្រែ ។

អ្នកជិតខាងៈ អានេះជម្លោះគ្នាតែដុំថ្ម ។

កុសលៈ មានរឿងកំប្លែងគេមួយ គេមិនយកអីគេ ខាងវៀតណាមគេចង់បានតែដីស្រែ ពួកថៃ ល្ងង់ណាស់ចង់បានតែដុំថ្ម ។

អ្នកជិតខាងៈ យ៉ាប់ហើយខ្មែរយើង ។

កុសលៈ អ៎ចឹងមានអីបន្ថែម ថ្ងៃខ្ញុំចង់ជួបអ៊ំ ក្រុមការងារខ្ញុំចង់ជួបអ៊ំ អ៊ំនៅផ្ទះទេ នៅមុខនេះ?

អ្នកជិតខាងៈ បាទ!

កុសលៈ ជួបអ៊ំសួររឿងបន្ថែម ។ អ៊ីចឹងខ្ញុំបញ្ជាក់ម្តងទៀត សរុបសេចក្តីមក ដើម្បីសន្តិភាព ដើម្បីការផ្សះផ្សារ តើលោកពូយល់ថាអ្វីដែលកើតឡើងនៅក្នុង របបកម្ពុជាប្រជាធិបតេយ្យ គួរតែបំភ្លេចចោលទៅ ឬយើងយករំលឹកឡើងវិញ ឬយ៉ាងណា?

ទូចៈ រំលឹកឡើងវិញ មិនឆាយចប់ ។

កុសលៈ ឈោមសងឈោម ។ ចុះក្មេងៗជំនាន់ក្រោយគួរតែរៀនសូត្រ គួរតែដឹង?

ទូចៈ រឿងប្រវត្តិសាស្ត្រចេះតែចារទុកអ៊ីចឹង កំឲ្យខាងក្រោយធ្វើតំរាប់តាម ។

កុសលៈ ប៉ុន្តែមិនគួរយកមករំលឹក?

ទូចៈ បាទ! អ្នកជិតខាង «រំលឹកចេះតែទៅទៀត» ។

កុសលៈ ហើយមួយទៀត ដូចថារាល់ថ្ងៃ រាជរដ្ឋាភិបាលហើយនិងអន្តរជាតិធ្វើការ មានការកាត់ទោសដល់មេធំៗហ្នឹងក៏ត្រឹមហ្នឹងទៅ? ចង់និយាយអ៊ីចឹង?

ទូចៈ បាទ!

កុសលៈ ដើម្បីបញ្ចប់ត្រឹមហ្នឹងកំឲ្យមានតទៅទៀត ។ អ៊ីចឹងពូគាំទ្រខ្លាំងកុំឲ្យមានតទៅទៀត?

ទូចៈ កុំឲ្យតទៅទៀត តទៅទៀតវាអត់មានប្រយោជន៍អីទេ គ្រាន់តែខាតបង់លុយដែលខំប្រឹងស្រាវជ្រាវហ្នឹង ។

កុសលៈ វាអាចប៉ះពាល់ដល់សតិអារម្មណ៍ប្រជាជនទេ ក្នុងតំបន់នេះ?

ទូចៈ ប្រជាជនគ្មានឈឺឆ្អាលអីផង ។ គ្រាន់តែខាតបង់ ។

កុសលៈ ក្រោមៗពីមុនមក?

ទូចៈ បាទ! អ្នកជិតខាង «ខ្សឹបខ្សាវគ្នា ដូចខ្ញុំឧទាហរណ៍ ថ្ងៃនេះគេយកមេទៅហើយ ថ្ងៃក្រោយខាងនេះគេ យកទៅមួយកងពល, ថ្ងៃក្រោយវរសេនាធំ, ថ្ងៃក្រោយ ទៀតកងវរៈ ថ្ងៃក្រោយទៀត មកដល់មេក្រុម, មេពួក យកទៅអស់រលីង អាហ្នឹង គ្រាន់តែព្រួយ» ។

កុសលៈ ខ្សឹបខ្សាវទេ តាមការពិតជាក់ស្តែង ។

អ្នកជិតខាងៈ បើថាយកទៅអចឹងសង្គ្រាមក៏វាកើតឡើងវិញ ឃើញតែកាប់សម្លាប់តែគ្នាឯង ។

កុសលៈ ខ្ញុំអស់សំនួរហើយ មានអីបន្ថែមទៀតទេលោកពូ?

ទូចៈ អត់ ។

កុសលៈ អរគុណច្រើនលោកពូ ។ ចាំមើលថ្ងៃខ្ញុំជួបលោកអ៊ំ ។

**«ចប់»**